ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី ៣៣*៤៧

លេខៈ ៣៩

ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៥ **នាមនាមប្រជារាស្ត្រខ្មែរ**

<u>សាលដីកា</u> **តុលាការកំពូល**

លេខៈ ២១២ បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៦

ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៦ ដោយមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ឌិត** | **មុន្ទី** | ជាប្រធាន |
| ២-លោក | ស៊ិន | ឌឹម | ជាចៅក្រម |
| ៣-លោក | សោម | សិរីវឌ្ឍ | ជាចៅក្រម |
| ៤-លោក | ប៉ែន | សារឿន | ជាចៅក្រមរបាយការណ៍ |
| ៥-លោក | យូរ | ឧត្តរា | ជាចៅក្រម |

ក្រឡាបញ្ជី

លោក **ម៉ៅ** **សុខណ្ណា**

តំណាងមហាអយ្យការ

លោក **ឈួន** **ចាន់ថា** ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ២២៤"ឈ"ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៤ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ២៩៧ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះ **ទួច** **រ៉ានី** (ជាចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៦០ឆ្នាំ ជាតិខ្មែរ មុខរបរគ្រូបង្រៀន ទីលំនៅភូមិប្រាសាទ ឃុំកំពង់ក្តី ស្រុកជីក្រែង ខេត្តសៀមរាប ។

មានមេធាវីអ្នកស្រី ណេត ចាវី ,

ចុងចម្លើយឈ្មោះ **ពិត** **ផា** (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៥៧ឆ្នាំ ជាតិខ្មែរ មុខរបរព្រះសង្ឃ ទីលំនៅភូមិថ្មី ឃុំគោកធ្លកក្រោម ស្រុកជីក្រែង ខេត្តសៀមរាប ។

មានមេធាវី លោក លួង សុខា ,

តតិយជនឈ្មោះ **សែម** **រុំ** (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ៦៦ឆ្នាំ ជាតិខ្មែរ

មុខរបរនៅផ្ទះ ទីលំនៅភូមិថ្មី ឃុំគោកធ្លកក្រោម ស្រុកជីក្រែង ខេត្តសៀមរាប ។

មានមេធាវីអ្នកស្រី មាស សុគន្ធា

**កម្មវត្ថុបណ្តឹង** : ប្តឹងទាមទារសុំចែកដីទិញរួមគ្នា

បានឃើញបណ្តឹងសាទុក្ខលេខ៩២៩ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៤ របស់ឈ្មោះ សែម រិច ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ២២៤"ឈ" ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៣៩ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៥ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី០៧-០៨-២០០៣ របស់ដើមចោទឈ្មោះនួន រ៉ានី ប្តឹងសុំចែកដីទំហំ១៧ម x ២៩ម ស្ថិតនៅភូមិចុងកៅស៊ូ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប មានព្រំខាងជើងទល់ដី លី ទី ខាងត្បូងទល់ដីសុវណ្ណគីរី និងដី យូ ដារ៉ា និងខាងកើតទល់ដីឈ្មោះភាព ខាងលិចទល់ដីផ្លូវលំ ជាមួយឈ្មោះគីក ជា ដោយសំអាងហេតុថាខ្លួនបានឈ្មោះគីកជាជាប្តីនៅឆ្នាំ១៩៩៣ ។ នៅឆ្នាំ១៩៩៤ ខ្លួន និងឈ្មោះគីក ជា បានចូលហ៊ុនគ្នាទិញដីនេះតំលៃ៥ជី៥ហ៊ុនមាស ពេលនោះឈ្មោះគីក ជា មានប្រាក់តែ១ជី៧ហ៊ុនមាសទេ ក្រៅពីនោះខ្លួនចេញទាំងអស់ នៅឆ្នាំ១៩៩៧ ខ្លួនបានចាក់ដីបំពេញអស់ប្រាក់ ១៤ជីមាស ពេលនោះឈ្មោះគីក ជា មានវ័យចាស់បានបួសជាព្រះសង្ឃ ។ ដីដែលខ្លួនបានទិញជាមួយគីក ជា ត្រូវបានកូនស្រីរបស់គាត់មកសង់រោងធ្វើការ៉េមគី ដោយគ្មានការព្រមព្រៀងពីខ្លួនទេ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ២៤២ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៣ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ក-ទទួលពាក្យបណ្តឹងចុះថ្ងៃទី០៧-០៨-២០០៣ របស់ដើមចោទ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

ខ-ទទួលយកសំណូមពររបស់ដើមចោទប្តឹងសុំឱ្យរុះរើរោងចេញ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ តែបដិសេធចោល ប្តឹងទាមទារដំនឹចិត្តដោយផ្ទុយនឹងគតិច្បាប់ ។

២-ទទួលពាក្យបណ្តឹងតបចុះថ្ងៃទី១៤-០៨-២០០៣ របស់តតិយជន ទុកជាត្រឹមត្រូវតាមទំរង់ តែត្រូវបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

៣-ប្រគល់ដីទំហំ១៣ម៉ែត្រ គុណនឹង២៩ម៉ែត្រ មានព្រំខាងជើងទល់ដីឈ្មោះគីក ជា ខាងត្បូងទល់ដីយូ ដារ៉ា និងហេង សុវណ្ណគីរី ,ខាងកើតទល់ដីភាព និង ខាងលិចទល់ផ្លូវ ស្ថិតនៅភូមិចុងកៅស៊ូ ឃុំស្លក្រាម ស្រុកសៀមរាប ខេត្តសៀមរាប ទៅឈ្មោះនួន រ៉ានី ជា

ដើមចោទ និងប្រគល់ដីទំហំ៩ម៉ែត្រ គុណនឹង ២៩ម៉ែត្រ មានព្រំខាងជើងទល់ដី លី ទី ,ខាងត្បូងទល់ដីនួន រ៉ានី ,ខាងកើតទល់ដីភាព និងខាងលិចទល់ផ្លូវលំ ស្ថិតនៅភូមិចុងកៅស៊ូដែរ ឱ្យទៅឈ្មោះគីក ជា ជាចុងចម្លើយ តាមការព្រមព្រៀងរបស់ដើមចោទ និងចុងចំលើយ ។

៤-សំរេចឱ្យឈ្មោះសែម វិច និងកូន រុះរើ រោងចេញពីដីរបស់ដើមចោទ ។

៥-បង្គាប់ឱ្យចុងចំលើយបង់ប្រាក់ប្រដាប់ក្តីគឺពន្ធចុះបញ្ជីក្តី និង ពន្ធហ្វឹង១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ៥០០០៛ បូករួម ៧០០០៛ ។ ប្រាក់នេះបានកាត់យកពីប្រាក់៧០០០៛ ដែលដើមចោទបានបង់ទុករួចហើយ កាលបើហួសឧទ្ធរណ៍ត្រូវបង្គាប់ឱ្យឈ្មោះគីក ជា បង់ពន្ធសមាមាត្រមួយភាគរយលើតំលៃដីបន្ថែមទៀត ដែលត្រូវដាក់ចូលថវិការដ្ឋ៨០% និងរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០% ។ ពន្ធសមាមាត្រនេះត្រូវបង្គាប់ឱ្យដើមចោទបង់ទុកមុនដែរ ទើបបង្គាប់ឱ្យចុងចំលើយសងប្រាក់នេះទៅដើមចោទវិញជាក្រោយ ។

៦-សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវឧទ្ធរណ៍កំណត់ពីរខែ គិតពីថ្ងៃនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ៦០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៣ របស់ឈ្មោះសែមវិច ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ២៨២ចុះថ្ងៃទី២៤ខែតុលា ឆ្នាំ២០០៣ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ត្រង់ចំណុចសេចក្តីវិនិច្ឆ័យទាំងមូលនៃសាលក្រម ។

បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៣ របស់ឈ្មោះនួន រ៉ានី ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ២៨២ចុះថ្ងៃទី២៤ខែតុលា ឆ្នាំ២០០៣ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ត្រង់ចំណុចលេខរៀងទី១ ចំណុច"ខ"នៃឃ្លាចុងក្រោយនៃសេចក្តីសំរេចថា"បដិសេធចោលការប្តឹងទាមទារជំងឺចិត្ត ដោយផ្ទុយនឹងគតិច្បាប់" ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១០០"ឃ" ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៨-១២-២០០៣ របស់ឈ្មោះសែម វិច ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៨-១២-២០០៣ របស់ឈ្មោះនួន រ៉ានី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

៣-តំកល់សាលក្រមរដ្ឋប្បវេណីលេខ ២៨២ ចុះថ្ងៃទី២៤-១០-២០០៣ របស់តុលាការខេត្តសៀមរាប ឧត្តរមានជ័យ ទុកជាបានការដដែល ។

៤-កាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ គឺពន្ធហ្វឹង និងពន្ធចុះបញ្ជីក្ដីចំនួន ២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ៤៥០៛ ចំណាយលើការប្រគល់ដីកាកោះចំនួន៥០០០៛ និងអាជ្ញាធរតុលាការចំនួន ៥.០០០៛ សរុប ១៣.០០០៛ ។

៥-សាលដីកានេះជំនុំជំរះជាសាធារណៈនៅថ្ងៃទី១៦-០៧-២០០៤ ចំពោះមុខគូក្ដី កំបាំងមុខតតិយជន និងប្រកាសជាសាធារណៈនៅថ្ងៃទី២៧-០៧-២០០៤ កំបាំងមុខគូក្ដី និង តតិយជន តែទុកជាចំពោះមុខគូក្ដី បើកផ្លូវប្ដឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងទាស់លេខ១២៦ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៤ របស់មេធាវីលួងសុខា ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១០០"ឃ" ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្ដីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ២២៤"ឃ"ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៤ របស់ សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងទាស់ចុះថ្ងៃទី០៥-១០-២០០៤ របស់លោកមេធាវីលួងសុខា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តំកល់សាលដីការដ្ឋប្បវេណីកំបាំងមុខលេខ១០០"ឃ"ចុះថ្ងៃទី២៧-៧-២០០៤ របស់សាលាឧទ្ធរណ៍ទុកជាបានការដដែល ។

៣-សាលដីកានេះ ជំនុំជំរះ ជាសាធារណៈនៅថ្ងៃទី១៦-១២-២០០៤ ចំពោះ មុខគូក្ដី និងតតិយជន និងប្រកាសជាសាធារណៈនៅថ្ងៃទី២១-១២-២០០៤ ចំពោះមុខចុងចំលើយ និងតតិយជន កំបាំងមុខដើមចោទ តែទុកជាចំពោះមុខ បើកផ្លូវប្ដឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ៥២៩ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៤ របស់ឈ្មោះ សែម រិច ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ២២៤"ឃ" ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៤ របស់ សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្ដីសំរេចទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០០៥ របស់ឈ្មោះសែម រ៉ុច ។

បានឃើញសារណាតបចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៥ របស់មេធាវីឈ្មោះណោតថាវី។

បានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលដីកាសាលាឧទ្ធរណ៍លេខ ២២៤"ឃ"ចុះថ្ងៃទី២១-១២-២០០៤ ដែលបានសំរេចសេចក្ដីមកនេះ មានលក្ខណៈត្រឹមត្រូវទាំង ទំរង់ និងគតិច្បាប់ ។

សូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់ ។

បានស្តាប់ចំលើយរបស់ឈ្មោះសែម វិច នាពេលសវនាការថា : កាលពីទិញដីប្តីខ្លួនយកលុយពីផ្ទះទៅទិញដីចូលគ្នាជាមួយនួន វ៉ានី ម្នាក់ពាក់កណ្តាល និងយកប្រាក់ខែគាត់៥ឆ្នាំ ទៅចាក់ដី ប្តីខ្លួនជាអ្នកទិញដីនេះ ខ្លួនមិនបានទៅទិញទេ តែគាត់ប្រាប់ខ្លួនថា អញយកលុយទៅទិញដី ។ ខ្លួនសំណូមពរ សុំយកដីពាក់កណ្តាល ។

បានស្តាប់ចំលើយរបស់ឈ្មោះនួន វ៉ានី នាពេលសវនាការថា :ប្តីខ្លួនមិនបានទិញដីចូលគ្នាទេ គឺខ្លួនទិញតែម្នាក់ឯងទេ គ្រាន់តែខ្លួនដាក់ឈ្មោះគាត់ប៉ុណ្ណោះ ។ ប្រាក់ទិញដីគឺប្រាក់ខ្លួនទាំងអស់ ប្រគល់ឱ្យម្ចាស់ដីដោយផ្ទាល់ គឺពុំមានវត្តមានអ្នកស្រីសែម វិច ទៅជាមួយទេ ។ ដីនេះគាត់សុំខ្លួនធ្វើការរ៉ែមកី ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីមាស សុគន្ធា ការពារឱ្យតតីយជន បានលើកឡើងថា : ក្នុងរឿងនេះ គឺជាការទាមទារដីរួម ។ លោកគីក ជា មិនទាន់បានលែងលះជាមួយសែមវិចទេ ហើយគាត់បានយកលុយពីប្រពន្ធទៅទិញដីជាមួយនួន វ៉ានី ។ បើនួន វ៉ានី ថាទិញដីនេះតែម្នាក់ឯង ចុះហេតុអ្វីបានជាគាត់ចែកដីនេះជាមួយគីក ជា ។នួន វ៉ានី ថា គាត់ប្រគល់លុយឱ្យម្ចាស់ដីផ្ទាល់ ចំណែកសែម វិច ថាកូនគាត់ ជាអ្នកប្រគល់លុយឱ្យម្ចាស់ដីដែរ ដូច្នេះសុទ្ធតែពុំមានភាពច្បាស់លាស់ដូចគ្នា ដែលទាមទារឱ្យសួរបញ្ជាក់ម្ចាស់ដី ចុះហេតុអ្វីបានជាពុំមានចំលើយសាក្សីដែលជាម្ចាស់ដីដែលបានលក់ដីនេះ មានន័យថា តុលាការថ្នាក់ក្រោមលប់បំបាត់សាក្សី ។

សំណូមពរ :សុំបង្វិលសំណុំរឿងទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះឡើងវិញ ព្រោះសាលាឧទ្ធរណ៍ពុំបានអង្កេតឱ្យបានច្បាស់លាស់ទេ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់ដើមចោទ តតីយជន និងសេចក្តីសន្និដ្ឋានរបស់មេធាវីតតីយជន .
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការកំពូល**

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៥២៩ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៤ របស់អ្នកស្រី សែម វិច ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបាន ដោយយោងតាមមាត្រា១៨នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា អ្នកស្រីសែម វិច មិនមានគុណសម្បត្តិតាមផ្លូវច្បាប់ក្នុងការទាមទារចែកដីទំនាស់ពាក់កណ្តាលដែលជាដីបានទិញរួមគ្នារវាងអ្នកស្រីនួន វ៉ានី និងលោកគីក ជា ឡើយ ពី

ព្រោះថា ពុំមានភស្តុតាងណាដែលបញ្ជាក់ថា អ្នកស្រីសែម រិច បានផ្តល់ប្រាក់ឱ្យលោកគីក ជា យកទៅទិញដីឡើយ ។

- យល់ឃើញថា តាមកំណត់ហេតុផ្សះផ្សាសំរុះសំរួលចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៣ របស់តុលាការខេត្តសៀមរាប គូភាគីបានស្រុះស្រួលគ្នាដោយលោក គីក ជា សុខចិត្តទទួលយកដី ទំហំ ៥ម x ២៥ម ផ្នែកខាងជើងនិងសល់ប៉ុន្មានត្រូវបានទៅអ្នកស្រីនួន រ៉ានី ពីព្រោះលោកបាន ចេញប្រាក់តែចំនួន មួយជីប្រាំពីរហ៊ុន ក្នុងចំនួនថ្លៃដីសរុប ១៥ជី ឯការចាក់ដីបំពេញអស់១៤ជី គឺ ជាប្រាក់របស់អ្នកស្រីនួន រ៉ានី ទាំងអស់។

- យល់ឃើញថា ដោយអ្នកស្រី សែម រិច ស្ថិតក្នុងចំណងអាពាហ៍ពិពាហ៍ ជាមួយលោក គីក ជា ដូច្នេះអ្នកស្រី សែម រិច មានសិទ្ធិត្រឹមតែទាមទារទ្រព្យដែលជាចំណែករបស់លោក គីក ជា តែប៉ុណ្ណោះ ។

- យល់ឃើញថា ការដែលមេធាវីតតិយជនលើកឡើងអំពីចំលើយសាក្សីថា ឈ្មោះគីក ម៉ាប់ ជាក្អូនឈ្មោះគីក ជា ជាអ្នកថ្លឹងមាសឱ្យម្ចាស់ដីនោះ ពុំអាចបដិសេធការអះអាងរបស់ម្ចាស់ដី ថា ខ្លួនពិតជាបានលក់ដីឱ្យ គីក ជា និងអ្នកស្រីនួន រ៉ានី មែននោះទេ ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចឱ្យចុងចំលើយបង់ពន្ធសមាមាត្រនោះគឺជា ការភ័ន្តច្រឡំ ពីព្រោះថា ភាគីចុងចំលើយនិងដើមចោទបានព្រមព្រៀងគ្នារួចហើយ ប៉ុន្តែភាគីតតិយ ជន ដែលប្តឹងសាទុក្ខ ដោយគ្មានគុណសម្បត្តិក្នុងរឿងក្តីនេះទេ ដូច្នេះភាគីតតិយជនត្រូវទទួលខុស ត្រូវលើប្រាក់ពន្ធសមាមាត្រ ដែលគប្បីតុលាការកំពូលកែតំរូវដោយឥតបង្អិល ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ២២៤"ឈ"ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់និងគតិច្បាប់ហើយ

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខដើមចោទ និងតតិយជន មិនចេញវី**

១-ទទួលបណ្តឹងសាទុក្ខលេខ ៥២៩ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៤ របស់អ្នកស្រីសែមរិច ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តំកល់សាលដីការដ្ឋប្បវេណីលេខ ២២៤"ឈ" ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៤ របស់ សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-រំបងួសប្រាក់ប្រដាប់ក្តីចំនួន១៥.០០០៛ ដែលដើមចោទ បានបង់ជូនគឺ :

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្វឹងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សំរាប់ជា រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់.

-ចំណាយលើការប្រគល់ដីការកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ ។

តំរូវឱ្យអ្នកស្រីសែម វិច សងប្រាក់ ១៩០០០៛ ទៅដើមចោទវិញ ។

បង្គាប់ឱ្យតតីយជនខាងចុងចំលើយ បង់ពន្ធសមាមាត្រតាមការកំណត់របស់តុលាការខេត្តសៀមរាប ។

៤-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៦។